# កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ និងក្រមសីលធម៌រវាងច្រកទេសន្តរប្រវេសន៍ការងារពីប្រទេសកម្ពុជាទៅប្រទេសថៃ

## បទបង្ហាញ

## ស្តីពី

## "ស្ថានភាពទូទៅនៃការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន"

នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
នៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ប្រព័ន្ធវីដេអូ

# មាតិកា

១. ស្ថានភាពទូទៅអំពីសមាគម និងទីភ្នាក់ងារជ្រើសរើសឯកជន

២. ក្របខណ្ឌស្ថាប័ន

៣. ក្របខណ្ឌគតិយុត្តជាតិ

៤. ការពង្រឹងការជ្រើសរើសពលករដោយក្រមសីលធម៌

៥. ការលើកសរសើរ និងការដាក់វិន័យទីភ្នាក់ងារជ្រើសរើសឯកជន

៦. ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន

៧. ក្របខណ្ឌគតិយុត្តអន្តរជាតិ

៨. កិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងទ្វេភាគី

# ១. ស្ថានភាពទូទៅអំពីសមាគម និងទីភ្នាក់ងារជ្រើសរើសឯកជន

- អនុលោមតាមអនុក្រិត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅបរទេស គឺធ្វើឡើងតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន។
- ដើម្បីបានក្លាយជាទីភ្នាក់ងារជ្រើសរើសឯកជន គ្រប់នីតិបុគ្គលឯកជន ត្រូវស្នើសុំការអនុញ្ញាត (អាជ្ញាប័ណ្ណ) មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបានការអនុញ្ញាតក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ និងកម្មសិក្សាការីទៅធ្វើការនៅប្រទេសបរទេស តាមប្រទេសគោលដៅនីមួយៗ ដោយមានកាតព្វកិច្ចសំខាន់ គឺការចុះកិច្ចសន្យា ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ក. អំពីសមាគម

- ដើម្បីពង្រឹងប្រសិទ្ធភាពបន្ថែមទៀត ក្នុងការគោរពច្បាប់ និងបទប្បញ្ញត្តិជាតិ ក៏ដូចជាបទដ្ឋានអន្តរជាតិ ក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់បានចងក្រងបង្កើតបានជាសមាគមសមាគមទីភ្នាក់ងារចំនួន០២ គឺ៖

១-សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) មានសមាជិកចំនួន ៥១ ក្រុមហ៊ុន

២-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) មានសមាជិកចំនួន ៥៧ ក្រុមហ៊ុន។

# ១. ស្ថានភាពទូទៅអំពីសមាគម និងទីភ្នាក់ងារជ្រើសរើសឯកជន (ត)

## ខ. អំពីទីភ្នាក់ងារជ្រើសរើសឯកជន

គិតត្រឹម**ខែកញ្ញា ឆ្នាំ២០២១** មានទីភ្នាក់ងារជ្រើសរើសឯកជន សរុបចំនួន **១២៦** ដែលក្នុងនោះ៖

- ក្រុមហ៊ុន បាននិងកំពុងដំណើរការសរុបចំនួន **១១៩ ក្រុមហ៊ុន**
- ក្រុមហ៊ុន បានផ្អាកសកម្មភាពដំណើរការសរុបចំនួន **០៧ ក្រុមហ៊ុន។**

ទីភ្នាក់ងារជ្រើសរើសឯកជន ដែលបានបញ្ជូនពលករ និងកម្មសិក្សាការីទៅធ្វើការនៅតាមបណ្តាប្រទេសនីមួយៗ រួមមាន៖

១- ថៃមានចំនួន **៩៤ ក្រុមហ៊ុន**

២- ម៉ាឡេស៊ីមានចំនួន **៩០ ក្រុមហ៊ុន**

៣- ជប៉ុនមានចំនួន **១១៤ ក្រុមហ៊ុន**

៤- សឹង្ហបុរីមានចំនួន **២៤ ក្រុមហ៊ុន**

៥- តំបន់រដ្ឋបាលពិសេសហុងកុងមានចំនួន **១១ ក្រុមហ៊ុន**

៦- អារ៉ាប់ប៊ីសាអូឌីតមានចំនួន **៤១ ក្រុមហ៊ុន**

៧- រដ្ឋគូវ៉ែតមានចំនួន **៣៩ ក្រុមហ៊ុន**

៨- រដ្ឋកាតាមានចំនួន **៣៩ ក្រុមហ៊ុន។**

# ២. ក្របខណ្ឌស្ថាប័ន

- **អនុក្រឹត្យលេខ ១៩០ អនក្រ.បក** ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន បានកំណត់ឱ្យក្រសួងការងារ **និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ** ដោយ **សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ។**
- **នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម** ជាអង្គភាពសេនាធិការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចត្រួតពិនិត្យ សម្របសម្រួល អនុវត្ត និងគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន ព្រមទាំងទទួលខុសត្រូវ៖

  ១- ការផ្តល់ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC)។

  ២- ការចុះត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសឯកជន។

  ៣- ការទទួល និងដោះស្រាយវិវាទ (បណ្តឹង) របស់ពលករទេសន្តរប្រវេសន៍ខ្មែរ។

  ៤- ការអប់រំណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅបរទេស។

  ៥- ការគ្រប់គ្រង និងការរក្សាទុកទិន្នន័យស្ថិតិពលករទេសន្តរប្រវេសន៍ខ្មែរ។

# ២. ក្រុមខណ្ឌស្ថាប័ន (ត)

៦- ប្រឹក្សាយោបល់ និងដោះស្រាយរាល់បញ្ហាពាក់ព័ន្ធសម្រាប់ពលករទេសន្តរប្រវេសន៍។

៧- ប្រឹក្សាយោបល់អំពីឱកាសការងារ ការជួយរកការងារធ្វើ និងការបង្កើតមុខរបរខ្លួនឯង ដល់ពលករទេសន្តរប្រវេសន៍ខ្មែរដែលបានធ្វើមាតុភូមិនិវត្តន៍។

៨- ផ្តល់ប្រឹក្សាយោបល់ ពាក់ព័ន្ធពលករទេសន្តរប្រវេសន៍ខ្មែរទៅធ្វើការនៅបរទេស និង ប្រទេសគោលដៅ។

៩- គ្រប់គ្រងស្តីពីការផ្សព្វផ្សាយព័ត៌មាន អំពីការជ្រើសរើសពលករទេសន្តរប្រវេសន៍ខ្មែរ តាមគ្រប់មធ្យាបាយ។

១០- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយពាក់ព័ន្ធនឹងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និង គ្រប់គ្រងពលករទេសន្តរប្រវេសន៍ខ្មែរ ជាមួយទីភ្នាក់ងារជ្រើសរើសឯកជន។

# ៣. ក្របខណ្ឌគតិយុត្តជាតិ

## ក. បទដ្ឋានគតិយុត្តជាតិ

១. អនុក្រឹត្យលេខ ១៩០អនក្រ.បក ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១១ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន

២. ប្រកាសលេខ០៤៥/១៣ ក.ប/ប្រ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យប្រើប្រាស់ពាក្យគន្លឹះនៅក្នុងអនុក្រឹត្យលេខ១៩០ អនក្រ.បក

៣. ប្រកាសលេខ០៤៦/១៣ ក.ប/ប្រ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីដំណើរការជ្រើសរើស និងការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរ

៤. ប្រកាសលេខ០៤៧/១៣ ក.ប/ប្រ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីទីភ្នាក់ងារជ្រើសរើសឯកជន

៥. ប្រកាសលេខ២៤៩ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីយន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍

# ៣. ក្របខណ្ឌគតិយុត្តជាតិ (ត)

**ក. បទដ្ឋានគតិយុត្ត (ត)**

៦. ប្រកាសលេខ២៥០ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន

៧. ប្រកាសលេខ២៥១ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការលើកសរសើរ និងការដាក់វិន័យទីភ្នាក់ងារជ្រើសរើសឯកជន

៨. ប្រកាសលេខ២៥២ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីសេវារបស់ទីភ្នាក់ងារជ្រើសរើសឯកជននៅកន្លែងធ្វើការ និងការធ្វើមាតុភូមិនិវត្តន៍

៩. ប្រកាសលេខ២៥៣ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យប្រើប្រាស់បទដ្ឋានអប្បបរមាកិច្ចសន្យាសេវារកការងារឱ្យធ្វើនៅបរទេស។

១០. កិច្ចសន្យារវាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន

១១. កិច្ចសន្យាសេវារកការឱ្យធ្វើរវាងទីភ្នាក់ងារជ្រើសរើសឯកជន និងពលករ។

# ៣. ក្របខណ្ឌគតិយុត្តជាតិ (ត)

## ខ. គោលនយោបាយជាតិ

១- គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥

២- គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣

៣- កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣

៤- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩- ២០២៣)។

# ៤. ការពង្រឹងការជ្រើសរើសពលករដោយក្រមសីលធម៌

## បទបញ្ញាទាក់ទងនឹងការជ្រើសរើសដោយក្រមសីលធម៌៖

- ប្រកាសលេខ ០៤៦/១៣ ក.ប/ប្រ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីដំណើរការជ្រើសរើស និងការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរ
- ប្រកាសលេខ ២៥០ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន
- ក្រមប្រតិបត្តិសម្រាប់សមាគម និងទីភ្នាក់ងារជ្រើសរើសពលករ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**អគ្គនាយកដ្ឋានការងារ**
**លេខ:** ១៤២៧១ **កប/អក**

## លិខិតឧទ្ទេសនាម

**យោង៖** -ចំណារដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤
-អនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១១
-ប្រកាសលេខ០៤៦/១៣ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-លិខិតលេខ០២៦/១៩MAC ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ របស់សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា

បានឧទ្ទេសនាមភ្នាក់ងារ **ក្រុមហ៊ុន 5 លីវ៉េ ប៊ែននីហ្វីត សឺវីស ឯ.ក** និងក្រុមហ៊ុន **វី.អិល.អិម. យូមេន រីសសស៍ ឯ.ក** ដូចខាងក្រោម៖

១- លោកស្រី **ព្រហ្ម ចាន់ថាវរី** ថ្ងៃខែឆ្នាំកំណើត ១២ មករា ១៩៧៣ លេខប័ណ្ណ ៖ MAC000564
២- លោក **សួន សារ៉េន** ថ្ងៃខែឆ្នាំកំណើត ១០ មេសា ១៩៧៥ លេខប័ណ្ណ ៖ MAC000381

**ដើម្បី :** ចុះទៅផ្សព្វផ្សាយ និងជ្រើសរើសពលករនៅតាមបណ្តារាជធានី-ខេត្ត។
**កាលបរិច្ឆេទចេញប័ណ្ណ** : ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩
**កាលបរិច្ឆេទផុតកំណត់** : ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៩

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៩
**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ**

**សេង_សក្ដា**

ចម្លងជូន
-នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
-សាមីខ្លួន : ដើម្បីអនុវត្ត:
-ឯកសារ-កាលប្បវត្តិ

សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា
**MANPOWER ASSOCIATION OF CAMBODIA**

## ប័ណ្ណសម្គាល់ភ្នាក់ងារជ្រើសរើស

No. MAC000381



ឈ្មោះ : **សួន សារ៉េន** ភេទ : ប្រុស
ថ្ងៃខែឆ្នាំកំណើត : ១០ មេសា ១៩៧៥
មុខងារ : ភ្នាក់ងារក្រុមហ៊ុន
 វី.អិល.អិម. យូមេន រីសសស៍ ឯ.ក
ផុតកំណត់ : ២៨ ធ្នូ ២០១៩

**បម្រាម**

ប័ណ្ណសំគាល់ភ្នាក់ងារជ្រើសរើសនេះជាប័ណ្ណភ្នាក់ងារផ្លូវការរបស់ក្រុមហ៊ុនដែលជាសមាជិករបស់សមាគម និងត្រូវបានពាក់ក្នុងកំឡុងពេលធ្វើការ និងបំពេញភារកិច្ចក្រុមហ៊ុន ហើយមិនត្រូវអនុញ្ញាតឱ្យអ្នកដ៏ទៃខ្ចីប្រើជាដាច់ខាត បើពុំនោះទេសមាគមនឹងធ្វើការដកហូតមកវិញ និងទទួលខុសត្រូវមុខច្បាប់ជាធរមាន។

ទូរស័ព្ទលេខ:012525631/012600997/077467777

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**អគ្គនាយកការងារ**

**សេង_សក្ដា**

**ប្រធានសមាគម**

**អន_ប៊ុនហាក់**


ACRA
សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា
ASSOCIATION OF CAMBODIAN RECRUITMENT AGENCIES
RC003-2014
សុខ សុវណ្ណឧត្តម
ភ្នាក់ងារក្រុមហ៊ុន អ៊ឹង វិទ្ធី គ្រុប


ប័ណ្ណសំគាល់ខ្លួន
ប័ណ្ណសំគាល់ខ្លួននេះគឺជាប័ណ្ណសំគាល់ខ្លួនភ្នាក់ងារជ្រើសរើសពលករផ្លូវការរបស់ក្រុមហ៊ុនស្របច្បាប់ដែល ជាសមាជិករបស់សមាគមនិងត្រូវបានពាក់ក្នុងពេលធ្វើការ និងបំពេញភារកិច្ចក្រុមហ៊ុន។
ប័ណ្ណសំគាល់ខ្លួននេះមិនអនុញ្ញាតឲ្យអ្នកដទៃខ្ចីប្រើជាដាច់ខាតបើពុំនោះទេ សមាគមនឹងធ្វើការដកហូតមកវិញ និងទទួលខុសត្រូវមុខច្បាប់ជាធរមាន។ ប្រសិនបើរើសបានសូមមេត្តាបញ្ជូនប័ណ្ណនេះមកសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា អាសយដ្ឋានផ្ទះលេខ 43 E1 ផ្លូវលេខ 271 សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។
ទូរសព្ទលេខ 097 37 38 038
ប្រធាន
ឧកញ៉ា អ៊ឹង ស៊ាងវិទ្ធី
ACRA
№ 0003

# ៥. ការលើកសរសើរ និងការដាក់វិន័យទីភ្នាក់ងារជ្រើសរើសឯកជន

- ប្រកាសលេខ២៥១ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការលើកសរសើរ និងការដាក់វិន័យទីភ្នាក់ងារជ្រើសរើសឯកជន៖

**ក. ការលើកសរសើរ ៖** មានចំណាត់ថ្នាក់ ៤កម្រិត៖

កម្រិត ១៖ ល្អណាស់ (Very good)

កម្រិត ២៖ ល្អ (Good)

កម្រិត ៣៖ មធ្យម (Fair)

កម្រិត ៤៖ ខ្សោយ (Poor)

# ៥. ការលើកសរសើរ និងការដាក់វិន័យទីភ្នាក់ងារជ្រើសរើសឯកជន (ត)

## ខ. ការដាក់វិន័យ

- ចំពោះទីភ្នាក់ងារជ្រើសរើសឯកជនដែលអនុវត្តបានកម្រិត៤ នឹងត្រូវផ្អាកសកម្មភាពបណ្តោះអាសន្នមួយរយៈពេលដែលមិនលើសពី១ឆ្នាំ ដើម្បីធ្វើការកែតម្រូវ។
- បន្ទាប់មកនឹងធ្វើការវាយតម្លៃជាថ្មី ដើម្បីទទួលបានការអនុញ្ញាតឱ្យធ្វើសកម្មភាពបន្ត។
- ក្នុងពិនិត្យពិនិត្យឃើញថាទីភ្នាក់ងារជ្រើសរើសឯកជន បានអនុវត្តផ្ទុយនឹងច្បាប់ និងបទបញ្ញាជាធរមាន ក្រសួងត្រូវសហការជាមួយ ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចកសាងនីតិវិធីអនុវត្តតាមផ្លូវច្បាប់។
- ការបញ្ឈប់ការអនុញ្ញាតជាស្ថាពរ ក្នុងករណីទីភ្នាក់ងារជ្រើសរើសឯកជន មិនអនុវត្តតាមគោលការណ៍ណែនាំ និងបទបញ្ញាជាធរមាន និងចំពោះសកម្មភាពជាក់ស្តែងទាំងឡាយណាដែលបានប្រព្រឹត្តិផ្ទុយទៅនឹងបទបញ្ញាច្បាប់ត្រូវចាត់ចែងតាមនីតិវិធីប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច។

# ៦. ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន

ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន (Code of Conduct) មាន១២ មាត្រា៖

១. គោរពចំពោះ និងអនុវត្តច្បាប់ជាតិ ព្រមទាំងគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ

២. គោរពចំពោះ លើការទំនាក់ទំនង ភាពច្បាស់លាស់ និងតម្លាភាពក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម

៣. គោរពចំពោះ និងចូលរួមកាត់បន្ថយថ្លៃចំណាយបន្ទាប់បន្សំនិងថ្លៃសេវាសម្រាប់ការធ្វើទេសន្តរប្រវេសន៍

៤. គោរពចំពោះ និងអនុវត្តការជ្រើសរើស នៃកិច្ចសន្យាសេវារកការងារឲ្យធ្វើ និងកិច្ចសន្យាការងារ

៥. គោរពចំពោះ និងការការពារទិន្នន័យ និងការរក្សាការសម្ងាត់

៦. គោរពចំពោះ ការទទួលស្គាល់ជំនាញ និងគុណវុឌ្ឍិវិជ្ជាជីវៈ

# ៦. ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន(ត)

៧. គោរពចំពោះ និងការផ្តល់ព័ត៌មានស្តីពីទេសន្តរប្រវេសន៍ និងការផ្តល់ការណែនាំតម្រង់ទិស មុនពេលចេញដំណើរជាចាំបាច់

៨. គោរពចំពោះ និងផ្តល់ការដោះស្រាយវិវាទដោយយន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍

៩. គោរពចំពោះ និងធ្វើប្រត្តិបត្តិការបញ្ជូនពលករទៅធ្វើការងារនៅក្រៅប្រទេសតែនៅក្នុងកិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់គ្នា (MOU) ដែលអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

១០. គោរពចំពោះ និងការការពារសិទ្ធិពលករ ដែលធ្វើការងារនៅប្រទេសគោលដៅ

១១. គោរពចំពោះ និងគាំទ្រការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មពលករទេសន្តរប្រវេសន៍

១២. គោរពចំពោះ និងធ្វើឲ្យមានសុវត្ថិភាព សេរីភាពនៃការបម្លាស់ទីគ្រប់ដំណាក់កាលនៃការធ្វើទេសន្តរប្រវេសន៍

# ៧. ក្របខណ្ឌគតិយុត្តអន្តរជាតិ

## ក. អនុសញ្ញាអន្តរជាតិ

១- អនុសញ្ញាអង្គការ ILO លេខ ១៤៣ ស្តីពីទេសន្តរប្រវេសន៍ក្នុងលក្ខខណ្ឌរំលោភបំពាន និងការលើកកម្ពស់សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មលើពលករទេសន្តរប្រវេសន៍ (ឆ្នាំ១៩៧៥)។

២- អនុសញ្ញាអង្គការ ILO លេខ ១៨១ ស្តីពីភ្នាក់ងារមុខរបរឯកជន (ឆ្នាំ១៩៩៧)។

## ខ. លិខិតូបករណ៍អាស៊ាន

១- សេចក្តីថ្លែងការណ៍ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករ ទេសន្តរប្រវេសន៍។

២- ឯកច្ឆ័ន្ទភាពស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍។

# ៨. កិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងទ្វេភាគី

## ក. កិច្ចសហប្រតិបត្តិការ

ដើម្បីពង្រឹងសមត្ថភាព ក៏ដូចជាគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ៖

- អង្គការអន្តរជាតិខាងការងារ (ILO)
- អង្គការអន្តរជាតិខាងទេសន្តរប្រវេសន៍ (IOM)
- អង្គការ UN Women
- ដៃគូពាក់ព័ន្ធផ្សេងទៀត។

# ៨. កិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងទ្វេភាគី (ត)

## ខ. កិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា

- ប្រទេសថៃ៖
  - អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤។
  - អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៏ស្តីពីកិច្ចសហប្រតិបត្តិការ នៃវិស័យការងារ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៥។
  - កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់កម្លាំងពលកម្មរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៏ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៥។

# ៨. កិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងទ្វេភាគី (ត)

## ខ. កិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា (ត)

- **សាធារណរដ្ឋកូរ៉េ៖**
  - អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបញ្ជូនពលករទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េតាមរយៈប្រព័ន្ធអនុញ្ញាតមុខរបរ(EPS) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦។
- **ប្រទេសម៉ាឡេស៊ី៖**
  - អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ី ស្តីពីការជ្រើសរើស និងប្រើប្រាស់ពលករ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥។
  - អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ី ស្តីពីការជ្រើសរើស និងការប្រើប្រាស់ពលករការងារផ្ទះ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥។

# ៨. កិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងទ្វេភាគី (ត)

## ខ. កិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា (ត)

- **ប្រទេសជប៉ុន៖**
  - អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងយុត្តិធម៌ ក្រសួងការបរទេស ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព និងអគ្គនាយកដ្ឋានប៉ូលីសជាតិនៃប្រទេសជប៉ុន និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីក្របខណ្ឌសម្រាប់ភាពជាដៃគូព័ត៌មានសម្រាប់ប្រតិបត្តិការសមស្រប នៃប្រព័ន្ធទទួលយកធនធានមនុស្សបរទេសដោយមានឋានៈនៃការស្នាក់នៅ នៃ "ពលករជំនាញ" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩
  - អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការលើកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេស ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧។
- **តំបន់រដ្ឋបាលពិសេសហុងកុង៖**
  - អនុស្សរណៈនៃកិច្ចព្រមព្រៀងរវាងអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងសមាគមអភិវឌ្ឍន៍ធនធានមនុស្សកម្ពុជានៅហុងកុង នៃតំបន់រដ្ឋបាលពិសេសហុងកុង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧
  - សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ៤៣៣ សជណ.អវ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៧។

# ៨. កិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងទ្វេភាគី (ត)

## ខ. កិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា (ត)

- **ប្រទេសសិង្ហបុរី៖**
  - លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ១៤៩២ សជណ.អវ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២។
- **អារ៉ាប់ប៊ីសាអូឌីត៖**
  - កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសពលករ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦
  - កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសពលករការងារផ្ទះ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦។
- **រដ្ឋគូវ៉ែត៖**
  - អនុស្សរណៈនៃការយោគយល់គ្នាស្តីពីវិស័យផ្លាស់ប្តូរហត្ថពលកម្ម ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩។
- **រដ្ឋកាតា៖**
  - កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងការប្រើប្រាស់ហត្ថពលកម្មចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១។

# ៨. កិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងទ្វេភាគី (ត)

## ខ. កិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា (ត)

- **ប្រទេសវៀតណាម៖**
  - អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧។
- **ប្រទេសទីម័រឡេស្តេ៖**
  - អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦។
- **ប្រទេសហ្វីលីពីន៖**
  - អនុស្សរណៈនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦។
  - **សេចក្តីថ្លែងការណ៍រួម**ស្តីពីការការពារជនទេសន្តរប្រវេសន៍ និងពលករទេសន្តរប្រវេសន៍ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦។

# ៨. កិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងទ្វេភាគី (ត)

## ខ. កិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា (ត)

- ប្រទេសបង់ក្លាដែស៖
  - អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧។
- ប្រទេសឡាវ៖
  - អនុស្សរណៈនៃការយោគយល់គ្នាស្តីពីពីកិច្ចសហប្រតិបត្តិការនៃវិស័យការងារ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។

# សូមអរគុណ!